**រោងចក្រផលិតទឹកបរិសុទ្ធគូលែន**

*អត្ថបទខ្លីរៀបរៀងដោយ ៖ Henri S., Noray N. et Vincent D.*

ពេលយើងចូលទៅក្នុងរោងចក្រផលិតទឹកបរិសុទ្ធគូលែន វាមានបរិយាកាសហាប់បន្តិច និងអត់សូវមានខ្យល់ ហើយក្តៅតិចៗ។ ក្រៅពីនេះយើងឃើញថាទីធ្លារោងចក្ររាងតូច គ្របដណ្តប់ទៅដោយគដ្ឋពណ៌ខៀវ។ នៅក្នុងរោងចក្រមានអាហារដ្ឋាន បន្ទប់ប្រជុំ សួនច្បារមួយនៅខាងក្រៅ។ ពួកយើងបានឃើញកម្មកររោងចក្រផលិតដបទឹកសុទ្ធ និងបំពេញទឹកបរិសុទ្ធគូលែននៅក្នុងរោងចក្រជាមួយនឹងម៉ាស៊ីនធំៗជាច្រើន។ យើងបានឃើញសួនច្បារនៅខាងក្រៅរោងចក្រមួយធំណាស់។ គេយកទឹកបរិសុទ្ធចេញពីភ្នំគូលែន។

**សាលាបារាំងទិសបូព៌ា**

*អត្ថបទខ្លីរៀបរៀងដោយ ៖ Edward P. , Lucas U. et Darwin K.*

នៅពេលយើងទៅខេត្តសៀមរាប យើងបានទៅទស្សនា**សាលាបារាំងទិសបូព៌ា** (Ecole Française Extrême Orient)។ សាលានេះមានជំនាញខាងសិប្បកម្មផ្នាំងដី ខ្ទម និងរូបចម្លាក់ផ្សេងៗ។ នៅទីនោះមានបណ្ណាល័យដែលមានសៀវភៅឯកសារនិយាយអំពីប្រវត្តិខ្មម ថូ ផ្នាំងដី ព្រមទាំងមានការតាំងរូបសំណាក់ និងវត្ថុប្រើប្រាស់បុរាណៗដែលបានជីកកកាយរកឃើញពីបណ្តាខេត្តនានានៃប្រទេសកម្ពុជា។ នៅក្នុងបណ្ណាល័យក៏មានការបង្ហាញពីឯកសារវីដូនិយាយអំពីការផលិតផ្នាំងដីពីបណ្តាប្រទេសផ្សេងៗផងដែរ។

**អង្គរវត្ត**

*អត្ថបទខ្លីរៀបរៀងដោយ ៖ Kamonique T., Sammavatey S. et Jennisha L.*

ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ ពួកខ្ញុំបានទៅលេងអង្គរវត្តនៅខេត្តសៀមរាបជាមួយថ្នាក់5eme ទាំងអស់។ ពេលពួកខ្ញុំទៅដល់ គេឆែកលិខិតឆ្លងដែនរបស់ពួកខ្ញុំទាំងអស់គ្នាដើម្បីបញ្ជាក់ថាពួកខ្ញុំជាកូនខ្មែរ បើនរណាម្នាក់មិនមែនជាកូនខ្មែរ អ្នកនោះត្រូវបង់លុយ៣៦ដុល្លារ។ ពួកខ្ញុំបានទៅមើលរូបចម្លាក់នៅតាមជញ្ជាំងប្រាសាទ ប៉ុន្តែពួកខ្ញុំមិនបានឡើងទៅលើប្រាសាទអង្គរវត្តទេព្រោះមានមនុស្សច្រើនពេក។ ពួកខ្ញុំក៏បានឃើញអប្សរាមានធ្មេញដែរ នាងមើលទៅគួរឱ្យខ្លាចណាស់សម្រាប់ពួកខ្ញុំ។ ក្រោយពីបានទៅលេងប្រាសាទអង្គរវត្តរួច ពួកខ្ញុំមានអារម្មណ៍ថាពួកខ្ញុំបានរៀនអំពីប្រវត្តិរបស់ប្រទេសខ្មែរ និងសង្គ្រាមរវាងប្រជាជនខ្មែរ ចាម និងសៀម។ យើងបានដឹងថាប្រជាជនចិនបានជួយយើងនៅពេលសង្គ្រាម។ យើងបានដឹងអំពីល្បែងកម្សាន្តនាសម័យកាលនេះ ដូចជា ការជល់មាន់ ជល់ជ្រូកព្រៃ ជល់គោ ស្ទូចត្រី -ល-។ ពួកខ្ញុំក៏នឹកស្មានមិនដល់ថាខ្មែរយើងអាចសាងសង់ប្រាសាទដ៏ស្រស់ស្អាតនេះបាន។ ពួកខ្ញុំបានត្រឡប់មកវិញយ៉ាងសប្បាយរីករាយ៕

**ភូមិអណ្តែតទឹក**

*អត្ថបទខ្លីរៀបរៀងដោយ ៖ Munipich L., Vivian O. et Orfea N.*

នៅពេលព្រឹកថ្ងៃទី៣ យើងបានទៅទស្សនាភូមិអណ្តែតទឹក។ ពេលយើងជិះទៅកន្លែងទូករបស់យើង យើងបានជិះកាត់ផ្ទះអ្នកភូមិជាច្រើន។ អ្នកភូមិផ្លាស់ប្តូរទីកន្លែងដោយសារទូករបស់ពួកគេ។ សម្រាប់ចំណីអាហារ អ្នកភូមិអាចទៅនេសាទត្រីដោយផ្ទាល់ ឬអាចនឹងទិញបន្លែ ត្រី សាច់ និងផ្លែឈើ ដែលមានលក់នៅតាមទូក។ ផ្ទះរបស់អ្នកភូមិធ្វើមកអំពីឈើ ស័ង្កសី។ ពួកគាត់ប្រើប្រាស់ទឹកបឹងដែលពួកគាត់រស់នៅពីលើ ទៅតាមតម្រូវការប្រើប្រាស់

ប្រចាំថ្ងៃរបស់ពួកគាត់។ ពួកអ្នកភូមិញ៉ាំអាហារដូចជាត្រី បន្លែ និងចេក។ ពួកយើងបានឃើញសិស្សានុសិស្សជិះទូកទៅសាលារៀនរបស់ពួកគេ។

ពួកយើងមានអារម្មណ៍ភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលបានឃើញពីជីវភាពរបស់ពួកអ្នកភូមិអណ្តែតទឹក ដែលមានភាពខុសគ្នាពីការរស់នៅប្រចាំថ្ងៃរបស់ពួកយើង ព្រោះថាពួកគេរស់នៅលើទូក ត្រូវផ្លាស់ទីដោយប្រើទូក ឯពួកខ្ញុំផ្លាស់ទីដោយរថយន្ត ម៉ូតូ ឬមធ្យោបាយផ្សេងទៀត៕

**ល្ខោនស្បែក**

*អត្ថបទខ្លីរៀបរៀងដោយ ៖ Alika D., Ponnareay R. et William K.*

**តើរូបស្បែកត្រូវធ្វើដូចម្ដេច?**

ល្ខោនស្បែកធ្វើអំពីស្បែកគោ ឬស្បែកក្របី។ ការធ្វើស្បែកមានរយៈពេលជាងមួយសប្តាហ៍។ នៅពេលស្បែក មុនដំបូង ត្រូវយកស្បែកគោ ឬក្របី មកជៀឱ្យស្អាត រួចលាបថ្នាំពណ៌ខ្មៅ ហាលឱ្យស្ងួតសិន មានរយៈពេល៣ ទៅ៤ថ្ងៃ ទើបគេយកដែកមុតកោស ហើយចេញជារូបសត្វ រូបដើមឈើ រូបមនុស្ស ឬរូបយក្ស។ បន្ទាប់មកគេដាប់ស្បែក ឬឆ្លាក់ឱ្យចេញជារូបរាងទាំងនោះ។

**មុននឹងលេងល្ខោនស្បែក**

គឺចាប់ផ្តើមបង្ហាញតួអង្គនីមួយៗ ដែលត្រូវសម្តែង ហើយភាគច្រើនល្ខោនស្បែកគេសម្តែងនៅពេលយប់។ រាល់ពេលសម្តែងល្ខោនស្បែក ត្រូវតែមានភ្លេងអមជាមួយនឹងរូបភាព។ មុននឹងលេងល្ខោនស្បែក គេតែងតែបន់ស្រន់ព្រោះរូបស្បែកកំពុងតែដេក ដូចនេះគេបន់ស្រន់ឱ្យរូបស្បែកក្រោកឡើង ដើម្បីសម្តែងបានល្អ គួរជាទីពេញចិត្ត៕

**ប្រាសាទបាយ័ន**

*អត្ថបទខ្លីរៀបរៀងដោយ ៖ Philly P. et Myrabelle M.*

ពួកខ្ញុំបានទៅលេងប្រាសាទបាយ័ន។ នៅប្រាសាទនោះមានផ្ទាំងរូបចម្លាក់នៅលើថ្មជាច្រើន។ លោកគ្រូអ្នកគ្រូបានរៀបរាប់ពន្យល់ពីរូបចម្លាក់នីមួយៗ។ ក្នុងផ្ទាំងរូបចម្លាក់មួយ ពួកយើងបានឃើញរូបកងទ័ពខ្មែរ ឡាវ និងចិនប្រយុទ្ធគ្នា។ ពួកយើងទាំងអស់គ្នាមានអារម្មណ៍រំភើបជាខ្លាំង ដែលពួកយើងបានឃើញរូបចម្លាក់ទាំងនោះ។